កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

# សេចក្តីសង្ខេប

# នៃគោលនយោបាយទំនាស់

# ផលប្រយោជន៍

ហាត្ថាកសិករលីមីតធីត ឈរលើសុចរិតភាពប្រឆាំងនឹងទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងក្នុងប្រតិបត្តិការអាជីវកម្ម និងទីផ្សារដែលយើងកំពុងធ្វើអាជីវកម្ម។ គោលនយោបាយទំនាស់ផលប្រយោជន៍បានអនុម័តដោយក្រុមប្រឹក្សាភិបាលដែលតម្រូវអោយ ៖

I. បុគ្គលិកទាំងអស់គួរជៀសវាងនូវសកម្មភាពដូចខាងក្រោម៖

(1) ការប្រើប្រាស់ធនធាន កម្មសិទ្ធបញ្ញា សម្ភារៈ និងកម្មវិធី (Software) សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន លើកលែងតែមានការអនុញ្ញាតពីថ្នាក់គ្រប់គ្រង ។

(2) ឆ្លៀតយកឱកាសណាមួយឬព័ត៌មានដែលប្រមូលបានក្នុងកំឡុងពេលបំរើការជាមួយ HKL ដើម្បីទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ជាពិសេសលើអ្វីដែលទាក់ទងនឹងប្រយោជន៍ក្រុមហ៊ុន ។

II. បុគ្គលិកទាំងអស់ត្រូវតែធ្វើការរាយការណ៍ពីសកម្មភាពដូចខាងក្រោមជាលាយល័ក្ខអក្សរទៅអ្នកគ្រប់គ្រង និងនាយកដ្ឋានប្រតិបត្តិតាម៖

(1) គ្រប់សកម្មភាពខាងក្រៅ មិនថាផលប្រយោជន៍ហិរញ្ញវត្ថុ ឬទំនាក់ទំនងដែលអាចបណ្តាលអោយមានទំនាស់ផលប្រយោជន៍ ឬការលេចឡើងនូវទំនាស់ផលប្រយោជន៍ ។

(2) ការកាន់តំណែងនៅក្នុងស្ថាប័ន ដែលស្វែងរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ជាពិសេសប្រសិនបើស្ថាប័នដែលមានទំនាក់ទំនងជាមួយហាត្ថាកសិករ ឬអាចរំពឹងទុកថាជាជំនួយពី ហាត្ថាកសិករ ក្នុងពេលដែលកំពុងបំរើការងារ ។

(3) សមាជិកគ្រួសារដែលបំរើការងារអោយហាត្ថាកសិករ ឬក្រុមហ៊ុននៅក្នុងក្រុមអាជីវកម្មហិរញ្ញវត្ថុក្រុងស្រី ។

III. បុគ្គលិកទាំងអស់គួរជៀសវាងនូវសកម្មភាពប្រតិបត្តិការដូចខាងក្រោម៖

(1) ធ្វើឱ្យមានការចំណេញ ឬការបាត់បង់នៃផ្នែកហិរញ្ញវត្ថុលើការចំណាយរបស់អតិថិជន។

(2) ទទួលបានអត្ថប្រយោជន៍ពីការផ្តល់សេវាកម្មជូនអតិថិជនឬ ប្រតិបត្តិការដែលធ្វើឡើងក្នុងនាមជាតំណាងរបស់អតិថជន ដែលជាលទ្ធផលអាចមានការប៉ះពាល់ដល់អត្ថប្រយោជន៍អតិថិជន។

(3) ទំនាស់ផលប្រយោជន៍ណាមួយរវាងអតិថិជន មិនថាចំពោះផ្នែកអាជីវកម្មដែលខុស ឬដូចគ្នានឹងអតិថិជន។

(4) ទំនាស់ប្រយោជន៍ដទៃទៀត ដែលធ្វើអោយទីផ្សារទទួលរងនូវការខូចខាត។

IV. បុគ្គលិកដែលពាក់ព័ន្ធ ត្រូវធ្វើការបង្កើតនូវបាំងព័ត៌មានបណ្តោះអាសន្ន ជុំវិញផ្នែកណាមួយជាពិសេស ឬក្រុមការងារប្រតិបត្តិការដូចករណីខាងក្រោម៖

(1) ការទទួលនូវព័ត៌មានដែលអាចបណ្តាលអោយមានទំនាស់ផលប្រយោជន៍ រវាងអតិថិជន និង ហត្ថលេខសិករ ឬក្រុមហ៊ុន និងអតិថិជនដទៃទៀត។

(2) ពាក់ព័ន្ធទៅនឹងសក្តានុពលប្រតិបត្តិការប្រកួតប្រជែង។

(3) ការទទួលបានការបង្ហាត់បង្ហាញពីនាយកដ្ឋានប្រតិបត្តិតាម។

V. បុគ្គលិកពាក់ព័ន្ធដែលស្ថិតនៅក្នុងរបាំងព័ត៌មាន ត្រូវតែប្រតិបត្តិដូចខាងក្រោម៖

(1) រក្សាសុវត្ថិភាព និងរក្សាការសម្ងាត់នៃព័ត៌មានដែលបានការពារ។

(2) មិនត្រូវផ្តល់នូវព័ត៌មានដែលបានការពារទៅកាន់បុគ្គលណាម្នាក់ដែលស្ថិតនៅក្រៅរបាំងព័ត៌មានលុះត្រាតែមានការអនុញ្ញាតក្នុងការឆ្លងកាត់របាំង ទៅតាមនីតិវិធីដែលពាក់ព័ន្ធ។

VI. Wall Straddler មិនអាចមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ ត្រួតពិនិត្យងារមុខបញ្ចូលរាប់មិន) ប្រយោជន៍ផលទំនាស់មានដែលការប្រតិបត្តិនៃ ខាងសងភាគីទាំងមួយជា (អនុម័តការនិង ។ មកទៅវិញទៅ